ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
លេខៈ ៦៥៥/២៣ ន.ប.ធ.

# គោលការណ៍ណែនាំ

# ស្តីពី

# លក្ខខណ្ឌ និងនីតិវិធីក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ, ប្រកាសលេខ ០០៦ អ.ស.ហ./ប្រ.ក. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច, ប្រកាសលេខ ០០៣ អ.ស.ហ./ប្រ.ក. ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច, ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

ដើម្បីសម្រួលដល់ការយល់ដឹង និងការបំពេញកាតព្វកិច្ចក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច **និយ័តករបរធនបាលកិច្ច (ន.ប.ធ.)** សម្រេចចេញគោលការណ៍ណែនាំដូចខាងក្រោម÷

## ១-វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច

បុគ្គលដែលតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទូទៅ ដែលមានបំណងចូលរួមវគ្គបណ្តុះបណ្តាលនេះ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះមក **ន.ប.ធ.** ទៅតាមទម្រង់ ផ្តល់ឯកសារភ្ជាប់ និងបង់ថ្លៃចុះឈ្មោះដែលកំណត់ដោយ **ន.ប.ធ.**។

### ១.១-កម្មវិធីសិក្សា និងកាលបរិច្ឆេទនៃវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ

បុគ្គលដែលបានចុះឈ្មោះ ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច ទៅតាមកម្មវិធីសិក្សា និងកាលបរិច្ឆេទ ដែលកំណត់ដោយ **ន.ប.ធ.**។

### ១.២-វិធីសាស្ត្រនៃការរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ

**ន.ប.ធ.** អាចរៀបចំវគ្គបណ្តុះបណ្តាលក្នុងទម្រង់ដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ ជាភាសាខ្មែរ ដោយមានការបកប្រែជាភាសាអង់គ្លេស។

អាសយដ្ឋាន: អគារ ១៦៨F (ជាន់ទី៨) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamres 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរសព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh

វិញ្ញាសានៃការប្រឡងត្រូវបានរៀបចំឡើងក្នុងទម្រង់ជាសំណួរពហុចម្លើយជ្រើសរើស (Multiple-Choice Questions) ដែលមាន ២ (ពីរ) ភាសាគឺ ភាសាខ្មែរ និងភាសាអង់គ្លេស។

បុគ្គលដែលបានចុះឈ្មោះត្រូវមានវត្តមានយ៉ាងតិច ៦០ (ហុកសិប) ភាគរយនៃចំនួនម៉ោងបណ្តុះបណ្តាលសរុប ដើម្បីមានសិទ្ធិចូលរួមការប្រឡង។

បុគ្គលដែលមានសិទ្ធិចូលរួមការប្រឡងត្រូវគោរពតាមសេចក្តីណែនាំស្តីពីការប្រឡងគុណវុឌ្ឍិដែលកំណត់ដោយ **ន.ប.ធ.** ។

## ១.៣- ករណីមិនអាចចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ

ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអាចចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយ **ន.ប.ធ.** បុគ្គលនោះត្រូវដាក់លិខិតស្នើសុំពន្យារពេលចូលរួម និងភ្ជាប់ឯកសារបញ្ជាក់ពីមូលហេតុសមស្របមក **ន.ប.ធ.** ឱ្យបានយ៉ាងហោចណាស់ ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមវគ្គបណ្តុះបណ្តាល ដើម្បីអាចរក្សាប្រាក់ដែលបានបង់រួចសម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិនៅវគ្គបន្ទាប់។ ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអនុវត្តតាមការកំណត់ទេ នោះប្រាក់ដែលបានបង់ត្រូវចាត់ទុកជាអសារបង់។

ប្រាក់ដែលបានបង់រួចអាចត្រូវបានរក្សាទុកសម្រាប់បុគ្គលដែលបានចុះឈ្មោះ បានតែមួយលើកប៉ុណ្ណោះ។

## ១.៤- ករណីផ្លាស់ប្តូរសមាសភាពអ្នកចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ

បុគ្គលដែលបានចុះឈ្មោះអាចត្រូវបានស្នើសុំផ្លាស់ប្តូរ និងត្រូវភ្ជាប់ឯកសារបញ្ជាក់ពីមូលហេតុសមស្របមក **ន.ប.ធ.** ឱ្យបាន ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមវគ្គបណ្តុះបណ្តាល ដើម្បីអាចរក្សាប្រាក់ដែលបានបង់រួចសម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ។ ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអនុវត្តតាមការកំណត់ទេ នោះប្រាក់ដែលបានបង់ត្រូវចាត់ទុកជាអសារបង់។

ប្រាក់ដែលបានបង់រួចអាចត្រូវបានរក្សាទុកសម្រាប់បុគ្គលដែលបានចុះឈ្មោះជំនួសថ្មីបានតែមួយលើកប៉ុណ្ណោះ។

## ១.៥- ការធ្លាក់ដោយស្វ័យប្រវត្តិ

បុគ្គលដែលចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ នឹងត្រូវកំណត់ធ្លាក់ដោយស្វ័យប្រវត្តិក្នុងករណី បុគ្គលនោះស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

- បង្កឱ្យមានបញ្ហា ឬភាពមិនប្រក្រតីក្នុងអំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ឬមិនគោរពតាមគោលការណ៍នៃសេចក្តីណែនាំស្តីពីការប្រឡងគុណវុឌ្ឍិដែលកំណត់ដោយ **ន.ប.ធ.**។
- មានវត្តមានចូលរួមវគ្គបណ្តុះបណ្តាលតិចជាង ៦០(ហុកសិប) ភាគរយនៃចំនួនម៉ោងបណ្តុះបណ្តាលសរុប។
- អវត្តមាននៅក្នុងការប្រឡង។

## ១.៦- វិញ្ញាបនបត្របញ្ជាក់ការចូលរួម និងសុពលភាព

**ន.ប.ឆ.** នឹងផ្តល់វិញ្ញាបនបត្របញ្ជាក់ការចូលរួម ជូនបុគ្គលដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងបានប្រឡងជាប់ជាស្ថាពរ។

លទ្ធផលប្រឡងមានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ប.ឆ.** ប្រកាសលទ្ធផលប្រឡង។

## ២-កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច

ដើម្បីបន្តសុពលភាពលទ្ធផលប្រឡង ឬលទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត បុគ្គលដែលត្រូវបន្តសុពលភាព ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តមក **ន.ប.ឆ.** ទៅតាមទម្រង់ ផ្តល់ឯកសារភ្ជាប់ និងបង់ថ្លៃចុះឈ្មោះ ដែលកំណត់ដោយ **ន.ប.ឆ.** ឱ្យបាន ១៨ (ដប់ប្រាំបី) ថ្ងៃមុនសុពលភាពចាស់ផុតកំណត់។

### ២.១-កម្មវិធីសិក្សា និងកាលបរិច្ឆេទនៃកម្មវិធីអប់រំវិជ្ជាជីវៈបន្ត

បុគ្គលដែលបានចុះឈ្មោះ ត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ទៅតាមកម្មវិធីសិក្សា និងកាលបរិច្ឆេទ ដែលកំណត់ដោយ **ន.ប.ឆ.**។

### ២.២-វិធីសាស្ត្រនៃការរៀបចំកម្មវិធីអប់រំវិជ្ជាជីវៈបន្ត

**ន.ប.ឆ.** អាចរៀបចំកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងទម្រង់ដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ ជាភាសាខ្មែរដោយមានការបកប្រែជាភាសាអង់គ្លេស។

ដើម្បីអាចបញ្ចប់ការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តដោយជោគជ័យ បុគ្គលដែលបានចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តត្រូវបំពេញលក្ខខណ្ឌវត្តមាន យ៉ាងតិច ៨០ (ប៉ែតសិប) ភាគរយនៃចំនួនម៉ោងបណ្តុះបណ្តាលសរុប។

### ២.៣-ករណីមិនអាចចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត

ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអាចចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយ **ន.ប.ឆ.** បុគ្គលនោះត្រូវដាក់លិខិតស្នើសុំពន្យារពេលចូលរួម និងភ្ជាប់ឯកសារបញ្ជាក់ពីមូលហេតុសមស្របមក **ន.ប.ឆ.** ឱ្យបានយ៉ាងហោចណាស់ ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ដើម្បីអាចរក្សាប្រាក់ដែលបានបង់រួចសម្រាប់ចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តនៅវគ្គបន្ទាប់។ ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអនុវត្តតាមការកំណត់នេះ នោះប្រាក់ដែលបានបង់ត្រូវចាត់ទុកជាអសារបង់ និងត្រូវបានតម្រូវឱ្យដាក់ពាក្យស្នើសុំចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងសារជាថ្មី។

ប្រាក់ដែលបានបង់រួចអាចត្រូវបានរក្សាទុកសម្រាប់បុគ្គលដែលបានចុះឈ្មោះ បានតែមួយលើកប៉ុណ្ណោះ។

### ២.៤-ករណីផ្លាស់ប្តូរសមាសភាពអ្នកចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត

បុគ្គលដែលបានចុះឈ្មោះ អាចត្រូវបានស្នើសុំផ្លាស់ប្តូរ និងត្រូវភ្ជាប់ឯកសារបញ្ជាក់ពីមូលហេតុសមស្របមក

**ន.ប.ធ.** ឱ្យបាន ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្ដើមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ដើម្បីអាចរក្សាប្រាក់ដែលបានបង់រួចសម្រាប់ចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត។ ក្នុងករណីបុគ្គលដែលបានចុះឈ្មោះ មិនអនុវត្តតាមការកំណត់ទេ នោះប្រាក់ដែលបានបង់ត្រូវចាត់ទុកជាអសារបង់។

ប្រាក់ដែលបានបង់រួចអាចត្រូវបានរក្សាទុកសម្រាប់បុគ្គលដែលបានចុះឈ្មោះជំនួសថ្មីបានតែមួយលើកប៉ុណ្ណោះ។

**២.៥- ករណីដាក់ពាក្យស្នើសុំចុះឈ្មោះយឺតយ៉ាវ**

បុគ្គលដែលដាក់ពាក្យស្នើសុំចុះឈ្មោះចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តមក **ន.ប.ធ.** តិចជាង ១៨ (ដប់ប្រាំបី) ថ្ងៃមុនសុពលភាពលទ្ធផលប្រឡង ឬលទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តចាស់ផុតកំណត់ ឬក្រោយសុពលភាពលទ្ធផលប្រឡង ឬលទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តចាស់ផុតកំណត់ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះចូលរួមវគ្គបណ្ដុះបណ្ដាលនិងការប្រឡងសារជាថ្មី។

**២.៦- ការធ្លាក់ដោយស្វ័យប្រវត្តិ**

បុគ្គលដែលចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តនឹងទទួលលទ្ធផលធ្លាក់ដោយស្វ័យប្រវត្តិ ក្នុងករណីបុគ្គលនោះស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

- បង្កឱ្យមានបញ្ហា ឬភាពមិនប្រក្រតីក្នុងអំឡុងពេលចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត។
- មានវត្តមានចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត តិចជាង ៨០ (ប៉ែតសិប) ភាគរយនៃចំនួនម៉ោងបណ្ដុះបណ្ដាលសរុប។

**២.៧-វិញ្ញាបនបត្របញ្ជាក់ការចូលរួម និងសុពលភាព**

**ន.ប.ធ.** នឹងផ្ដល់វិញ្ញាបនបត្របញ្ជាក់ការចូលរួម ជូនបុគ្គលដែលបានបញ្ចប់ការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តដោយជោគជ័យ។

លទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត មានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលលទ្ធផលចាស់អស់សុពលភាព។

ថ្ងៃ សុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**